ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

# របាយការណ៍
## ឯកឧត្តម ជា ចាន់តូ ទេសាភិបាល ធនាគារជាតិនៃកម្ពុជា
## ថ្លែងក្នុងឱកាសការពារសេចក្តីព្រាងច្បាប់ស្តីពី ភតិសន្យាហិរញ្ញវត្ថុ ជាមួយសមាជិកសមាជិកានៃព្រឹទ្ធសភា
នៅព្រឹទ្ធសភា ថ្ងៃចន្ទ ទី១០ ខែមិថុនា ឆ្នាំ២០០៩

ជាបឋម ខ្ញុំបាទសូមគោរព :

- សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា ជាទីគោរពដ៏ខ្ពង់ខ្ពស់
- សម្តេច ស៊ីសុវត្ថិ ជីវន៍មុនីរក្ស អនុប្រធានទី១ នៃព្រឹទ្ធសភា
- ឯកឧត្តម ទេព ងន អនុប្រធានទី២នៃព្រឹទ្ធសភា
- ឯកឧត្តម លោកជំទាវ ជាសមាជិក សមាជិកានៃព្រឹទ្ធសភាដ៏ឧត្តុង្គឧត្តម ជាទីគោរព

ថ្ងៃនេះ ខ្ញុំបាទមានកិត្តិយសដ៏ខ្ពង់ខ្ពស់បំផុត ដោយបានទទួលការអញ្ជើញពីព្រឹទ្ធសភាដ៏ឧត្តុង្គឧត្តម និងដោយមានការចាត់តាំងពីរាជរដ្ឋាភិបាល ដើម្បីមកការពារសេចក្តីព្រាងច្បាប់ ស្តីពី **ភតិសន្យាហិរញ្ញវត្ថុ** នៅក្នុងសម័យប្រជុំពេញអង្គព្រឹទ្ធសភា ។

ឆ្លៀតឱកាសដ៏វិសេសវិសាលនេះ ខ្ញុំបាទសូមសម្តែងនូវអំណរគុណចំពោះ សម្តេច ឯកឧត្តម លោកជំទាវ សមាជិកសមាជិកានៃព្រឹទ្ធសភាដ៏ឧត្តុង្គឧត្តម ដែលបានជួយគាំទ្រសេចក្តីព្រាងច្បាប់នេះ ។ ខ្ញុំបាទសូមថ្លែងអំណរគុណផងដែរចំពោះ ឯកឧត្តម ប្រធានគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារនិងសវនកម្ម និងឯកឧត្តម លោកជំទាវ ជាសមាជិកសមាជិកានៃគណៈកម្មការទី២នៃព្រឹទ្ធសភាទាំងអស់ ដែលបានជួយគាំទ្រ ពិនិត្យ ពិភាក្សា សេចក្តីព្រាងច្បាប់នេះ ។

### សម្តេច ឯកឧត្តម លោកជំទាវ សមាជិក សមាជិកានៃព្រឹទ្ធសភា ជាទីគោរពដ៏ខ្ពង់ខ្ពស់

ខ្ញុំបាទសូមការអនុញ្ញាតដើម្បីជម្រាបជូនជ្រាបពី *(១)* -គោលបំណងនិងប្រវត្តិនៃការរៀបចំសេចក្តីព្រាងច្បាប់ និង *(២)* - រចនាសម្ព័ន្ធ និងសារៈសំខាន់ នៃសេចក្តីព្រាងច្បាប់នេះ ដូចតទៅ :

### I. គោលបំណងនិងប្រវត្តិនៃការរៀបចំសេចក្តីព្រាងច្បាប់

ជារួម សេចក្តីព្រាងច្បាប់ភតិសន្យាហិរញ្ញវត្ថុនេះ ជាច្បាប់ពិសេស មានលក្ខណៈបច្ចេកទេសទាំងទ្រឹស្តី និងការអនុវត្ត ។ ម្យ៉ាងទៀត ពាក្យពេចន៍ដែលប្រើប្រាស់នៅក្នុងសេចក្តីព្រាងច្បាប់នេះ ភាគច្រើនជាពាក្យពេចន៍បច្ចេកទេស

ដែលមើលមួយភ្លែតទៅហាក់ដូចជាពិបាកយល់ ប៉ុន្តែខ្ញុំបាទសូមជម្រាបថាពាក្យពេចន៍ទាំងអស់នេះ សុទ្ធសឹងតែជាពាក្យមានក្នុងវចនានុក្រមសម្តេច **ជួន ណាត** និងវចនានុក្រមផ្សេងៗទៀត និងពាក្យមួយចំនួនធំ សុទ្ធតែធ្លាប់មានប្រើក្នុងច្បាប់មុនៗ រួចហើយដែរ ។ ខ្ញុំបាទយល់ឃើញថា ពាក្យបច្ចេកទេសទាំងអស់នេះ បើទម្លាប់និយាយយូរៗទៅនឹងរត់មាត់ បើទម្លាប់សរសេរយូរៗទៅ នឹងរត់ដៃ ហើយបើទម្លាប់គិតយូរៗទៅ នឹងរត់គំនិតជាមិនខាន ។

ច្បាប់នេះ មានគោលបំណងអភិវឌ្ឍប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ និងសហគ្រាសធុនតូចនិងមធ្យមនៅកម្ពុជាតាមរយៈប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ ។

ខ្ញុំបាទសូមការអនុញ្ញាតដើម្បីជម្រាបជូន អំពីពាក្យបច្ចេកទេសខ្លះដែលប្រើក្នុងច្បាប់នេះ ដូចជា :

**១- *ភតិកម្ម*** : តាមវចនានុក្រម សម្តេច ជួន ណាត មានន័យថា "ការជួល ឬការឈ្នួល "

**២. *ភតិសន្យា*** : មានន័យថា "ការជួលដោយមានកិច្ចសន្យា" ។ ហើយពាក្យភតិសន្យានេះ ក៏ធ្លាប់បានប្រើនៅក្នុងក្រមរដ្ឋប្បវេណីផងដែរ ។ ភតិសន្យាមានពីរប្រភេទ *ទី១-* គឺភតិសន្យាប្រតិបត្តិការ (Operational Leasing) និង*ទី២*-គឺភតិសន្យាហិរញ្ញវត្ថុ (Financial Leasing) ។

***ទី១. ភតិសន្យាប្រតិបត្តិការ*** អាចហៅថា "ភតិសន្យាធម្មតា" ឬហៅដោយខ្លីថា "ភតិសន្យា" ។ ភតិសន្យាសំដៅដល់ការជួល*អចលនវត្ថុ* ក្នុងក្របខ័ណ្ឌសកម្មភាពរដ្ឋប្បវេណី (Civil act) ។ ប្រតិបត្តិការភតិសន្យានេះមានចែងក្នុងក្រមរដ្ឋប្បវេណី ដែលជាច្បាប់ទូទៅ (Droit Common) រួចហើយ ។ *ឧទាហរណ៍* ដូចជាការជួលអគារ ជួលផ្ទះ ជួលដី ។ល។ នេះ គឺជាប្រតិបត្តិការភតិសន្យាធម្មតាដែលប្រតិបត្តិការទាំងនេះត្រូវគ្រប់គ្រងដោយក្រមរដ្ឋប្បវេណី ។

***ទី២. ភតិសន្យាហិរញ្ញវត្ថុ*** សំដៅដល់ការជួល *ចលនវត្ថុរយៈពេលវែង* ចាប់ពី ១ឆ្នាំឡើងទៅក្នុងក្របខ័ណ្ឌសកម្មភាពពាណិជ្ជកម្ម (Commercial act) ។ ការជួលនេះមានទម្រង់ជាកិច្ចសន្យាពិសេស ហើយភាគច្រើនអនុវត្តតាមរយៈប្រតិបត្តិការធនាគារទៀតផង ។ ដោយសារប្រតិបត្តិការនេះ ពិសេស បានជាតម្រូវឱ្យចែងក្នុងច្បាប់ពិសេសដោយឡែក (Loi particulière) ដែលមានលក្ខណៈខុសប្លែកពីការជួលធម្មតា ។ *ឧទាហរណ៍* ការជួលចលនវត្ថុ ដូចជាគ្រឿងចក្រ ទព្វសម្ភារៈ និងគ្រឿងម៉ាស៊ីនផ្សេងៗ ។ល។ ក្នុងរយៈពេលវែង លើសពីមួយឆ្នាំ ។

**ខ្ញុំបាទសូមជម្រាបថា នៅក្នុងច្បាប់នេះ មានភាគីពាក់ព័ន្ធបីជាសំខាន់ គឺ :**

***ទី១. ភតិបតី*** (Leasor) : មានន័យថា "អ្នកជួលចលនវត្ថុឱ្យគេ " ។ តាមធម្មតា ភតិបតីអាចជាធនាគារ ឬអាចជាក្រុមហ៊ុនភតិសន្យាដែលត្រូវមានអាជ្ញាប័ណ្ណធ្វើប្រតិបត្តិការពីធនាគារជាតិនៃកម្ពុជា ។

***ទី២. ភតិកៈ*** (Leasee) : មានន័យថា "អ្នកសុំជួលចលនវត្ថុពីភតិបតី " ។ តាមធម្មតា ភតិកៈភាគច្រើនជា សហគ្រាសធុនតូចនិងមធ្យម (រោងម៉ាស៊ីនកិនស្រូវ កសិដ្ឋានចិញ្ចឹមសត្វ ក្រុមហ៊ុនដឹកជញ្ជូនអ្នកដំណើរ ។ល។) ឬជាអតិថិជនធម្មតា ដែលត្រូវការជួលគ្រឿងម៉ាស៊ីន គ្រឿងចក្រយកមកប្រើប្រាស់ ។

***ទី៣.*** **អ្នកផ្គត់ផ្គង់** (Supplier) **:** គឺជាអ្នកលក់ចលនវត្ថុដែលសមស្របតាមតម្រូវការរបស់ភតិកៈ ។ អ្នកផ្គត់ផ្គង់អាចជាក្រុមហ៊ុនលក់គ្រឿងចក្រ លក់រថយន្តជាដើម ។

**តើហេតុអ្វីបានជាចាំបាច់មានច្បាប់ភតិសន្យាហិរញ្ញវត្ថុ ?**

មូលហេតុមានច្រើន ប៉ុន្តែមុនចូលដល់ចំណុចនេះ ខ្ញុំបាទសូមជម្រាបជូន សម្តេច ឯកឧត្តម លោកជំទាវ ឱ្យបានជ្រាបពី ស្ថានភាពវិស័យធនាគារនៅកម្ពុជា នាពេលបច្ចុប្បន្ន ដូចខាងក្រោម :

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ប្រព័ន្ធធនាគារនៅកម្ពុជាមានការរីកចម្រើនគួរឱ្យកត់សំគាល់ ទាំងផ្នែកវិសាលភាព និងទំហំប្រតិបត្តិការ ហើយបានដើរតួនាទីស្នូលក្នុងការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា ។ ធនាគារមានតួនាទីយ៉ាងសំខាន់ក្នុងការប្រមូលប្រាក់បញ្ញើពីសាធារណជន ទោះតិចក្តីច្រើនក្តី ហើយធនាគារ ក៏បានផ្តល់ការប្រាក់ជូនអ្នកផ្ញើប្រាក់ទាំងនោះផងដែរ ។ តាមធម្មតា ប្រាក់បញ្ញើដែលប្រមូលបានពីសាធារណជនទាំងនេះ ត្រូវបានធនាគារនោះយកទៅឱ្យគេខ្ចីបន្តទៀត ។ ប៉ុន្តែបច្ចុប្បន្ន ការឱ្យខ្ចីនេះ ភាគច្រើន គឺជាការឱ្យខ្ចីរយៈពេលខ្លីសម្រាប់សកម្មភាពពាណិជ្ជកម្ម (Trade Finance ) ប៉ុណ្ណោះ ។

បច្ចុប្បន្ន ធនាគារនៅប្រទេសកម្ពុជា ពុំទាន់ហ៊ានផ្តល់ឥណទានសម្រាប់ជាដើមទុនអភិវឌ្ឍរយៈពេលវែងនៅឡើយទេ ។ ឧទាហរណ៍ចំនួន ៥ឆ្នាំ ឬ ១០ឆ្នាំ ពីព្រោះធនាគារខ្លាចបាត់បង់ប្រាក់របស់គេ ។ នេះ គឺជាឧបសគ្គមួយសម្រាប់វិនិយោគិនក្នុងការពង្រីកអាជីវកម្ម និងពង្រីកសហគ្រាសធុនតូចនិងមធ្យម (SME) របស់ខ្លួនឱ្យរីកចម្រើន ។ ដើម្បីពង្រីកអាជីវកម្ម វិនិយោគិនត្រូវការដើមទុនរយៈពេលវែង ប៉ុន្តែគាត់ពុំមានលទ្ធភាពស្វែងរកប្រភពទុនរយៈពេលវែងបាន ពីព្រោះធនាគារទាំងនោះមិនហ៊ានអោយខ្ចី ដោយសារគ្មានច្បាប់ការពារ និងធានាដល់ពួកគេ ។ អ្នកខ្វះទុនរយៈពេលវែងច្រើនជាងគេនៅកម្ពុជា បច្ចុប្បន្ននេះ គឺសហគ្រាសធុនតូចនិងមធ្យម (SME) ទោះបីខ្លួនមានគំនិតផ្តួចផ្តើមធ្វើអាជីវកម្មក៏ដោយ ក៏ពិបាកស្វែងរកដើមទុនខ្លាំងណាស់ ។

ដោយយល់ឃើញពីសេចក្តីត្រូវការដើមទុនយ៉ាងច្រើនរបស់សហគ្រាសធុនតូច និងមធ្យម (SME) ពិសេសដោយសហគ្រាសទាំងនេះ ទាំងនៅពេលបច្ចុប្បន្ន ក៏ដូចជានៅពេលអនាគត មានតួនាទីសំខាន់ណាស់ក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ច និងលើកកំពស់ជីវភាពរស់នៅរបស់ប្រជាជន ដូច្នេះហើយទើបនៅថ្ងៃទី២៣ ខែមិនា ឆ្នាំ២០០៦ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានណែនាំឱ្យធនាគារជាតិនៃកម្ពុជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងយុត្តិធម៌ ក្រសួងពាណិជ្ជកម្ម និងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រៀបចំឱ្យមានសេចក្តីព្រាងច្បាប់ភតិសន្យាហិរញ្ញវត្ថុនេះឡើង ដើម្បីទំលាយនូវភាពទាល់ច្រក ឬឧបសគ្គទាំងឡាយក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិស្របតាមយុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាល នាដំណាក់កាលទី២ នេះ ។

ខ្ញុំបាទសូមជម្រាបថា សេចក្តីព្រាងច្បាប់នេះត្រូវបានរៀបចំឡើង ក្រោមជំនួយបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ក្នុងក្របខ័ណ្ឌនៃផែនការជាតិសម្រាប់អនុវត្តនីតិកម្មស្តីពីការបំពេញតម្រូវការនិងលក្ខខណ្ឌរបស់អង្គការពាណិជ្ជកម្មពិភពលោក (WTO) ។ ខ្លឹមសារនៃសេចក្តីព្រាងច្បាប់នេះ ត្រូវបានពិភាក្សាសារចុះសារឡើងជា

ច្រើនសារនៅថ្នាក់អន្តរក្រសួង ហើយត្រូវបានអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី អនុម័តនៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០០៩ និងបញ្ជូនមករដ្ឋសភា ។ នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៩ ច្បាប់នេះ រដ្ឋសភាបានអនុម័ត និងបញ្ជូនមកព្រឹទ្ធសភា នៅថ្ងៃទី២៨ ខែឧសភា និងគណៈកម្មាធិការទី២នៃព្រឹទ្ធសភា បានពិនិត្យនិងអនុម័តនៅថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០០៩ នេះ ។

ចំពោះមូលដ្ឋានគតិយុត្តិនៃសេចក្តីព្រាងច្បាប់នេះ ខ្ញុំបាទសូមអនុញ្ញាត ពុំចាំបាច់ជម្រាបជូនឡើងវិញទេ ព្រោះមានចែងក្នុងសេចក្តីថ្លែងហេតុរបស់រាជរដ្ឋាភិបាលរួចហើយ ។

## II. រចនាសម្ព័ន្ធ និងសារៈសំខាន់ នៃសេចក្តីព្រាងច្បាប់

សេចក្តីព្រាងច្បាប់នេះ មាន៨ជំពូក និងចែកចេញជា ៣៨ មាត្រា ។ ជំពូកនីមួយៗមានអត្ថន័យសំខាន់ដូចតទៅ :

**ជំពូកទី ១** លើកឡើងអំពីបទប្បញ្ញត្តិទូទៅ មាន ៤ មាត្រា ។ ជំពូកនេះ កំណត់ពីគោលបំណង វិសាលភាពនៃភតិសន្យាហិរញ្ញវត្ថុ និងកំណត់និយមន័យនៃពាក្យបច្ចេកទេសសម្រាប់ប្រើនៅក្នុងច្បាប់នេះ ។

**ជំពូកទី ២** លើកឡើងអំពីកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ មាន៦ មាត្រា ។ ជំពូកនេះ កំណត់ពីទម្រង់បែបបទនៃកិច្ចព្រមព្រៀងភតិសន្យា ។ **តើកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុត្រូវមានលក្ខខណ្ឌអ្វីខ្លះ ?**

នៅក្នុងជំពូកទី២នៃច្បាប់នេះបានកំណត់ថា ដើម្បីបង្កើតកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុបាន លុះត្រាតែយ៉ាងហោចណាស់ ត្រូវមានលក្ខខណ្ឌអប្បបរមា ដូចខាងក្រោម :

*១-* ការពណ៌នាពីចលនវត្ថុដែលបានជួល

*២-* ចំនួនប្រាក់ ការកំណត់គ្រា និងរយៈពេលនៃការបង់ថ្លៃឈ្នួល

*៣-* កាលបរិច្ឆេទចាប់ផ្តើមភតិសន្យាហិរញ្ញវត្ថុ និង

*៤-* ហត្ថលេខារបស់ភតិបតី និងភតិកៈ ។

ទន្ទឹមនេះ ជំពូកទី២ ក៏មានបញ្ជាក់ពីការអនុញ្ញាតឱ្យមានប្រាក់ប្រាតិភោគនិងការទូទាត់សងភតិសន្យាជាមុន ការដាក់ស្លាកសម្គាល់ចលនវត្ថុសម្រាប់សម្គាល់កម្មសិទ្ធិរបស់ភតិបតី និងលទ្ធភាពអាចទូទាត់ថ្លៃឈ្នួលបានតាមរយៈមធ្យោបាយផ្សេងៗក្រៅពីរូបិយវត្ថុ ជាដើម ។

**ជំពូកទី ៣** លើកឡើងអំពីសិទ្ធិ និងកាតព្វកិច្ចរបស់ភតិបតី ដែលក្នុងនោះរួមមាន ១២ មាត្រា ។ ជំពូកនេះកំណត់ពីសិទ្ធិជា "ម្ចាស់កម្មសិទ្ធិ" របស់ភតិបតីលើចលនវត្ថុដែលបានជួល សិទ្ធិរបស់ភតិបតីក្នុងការទាមទារសំណង *ក្នុងករណី* មានការខូចខាតឬបាត់បង់ចលនវត្ថុដែលជួល ឬទាមទារចលនវត្ថុដែលបានជួលមកវិញ ក្នុងករណីដែលភតិកៈមិនគោរពតាមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ និងការស្វែងរកដំណោះស្រាយនៅពេលភតិបតីក្ស័យធនជាដើម ។

**ជំពូកទី ៤** លើកឡើងអំពីសិទ្ធិនិងកាតព្វកិច្ចរបស់ភតិកៈ ដែលក្នុងនោះរួមមាន ១០ មាត្រា ។ ជំពូកនេះកំណត់ពី កាតព្វកិច្ចរបស់ភតិកៈក្នុងការជ្រើសរើសចលនវត្ថុតាមលក្ខណៈបច្ចេកទេសដែលខ្លួនចង់បាន ។ ហើយបន្ទាប់ពីមានការប្រគល់សម្ភារៈត្រឹមត្រូវតាមកិច្ចព្រមព្រៀងផ្គត់ផ្គង់រួចហើយ ភតិកៈត្រូវទទួលយកចលនវត្ថុដែលបានជួល ។ ការទូទាត់សងថ្លៃឈ្នួលតាមពេលវេលាកំណត់ ការប្រើប្រាស់ចលនវត្ថុដោយត្រឹមត្រូវ ការទទួលខុសត្រូវក្នុងពេលមានការខូចខាតឬបាត់បង់ ការទទួលខុសត្រូវទិញការធានារ៉ាប់រង និងការកំណត់ពីសិទ្ធិ និងកាតព្វកិច្ចរបស់អ្នកផ្គត់ផ្គង់ផងដែរ ។

**តើភតិបតី និងភតិកៈមានសិទ្ធិនិងកាតព្វកិច្ចអ្វីខ្លះលើទ្រព្យសម្ភារៈដែលជាកម្មវត្ថុនៃភតិសន្យាហិរញ្ញវត្ថុ?**

ភាគីសំខាន់នៅក្នុងច្បាប់នេះ មានបីគឺ ភតិបតី ( *អ្នកឱ្យគេជួល*) ភតិកៈ ( *អ្នកសុំជួលគេ*) និងអ្នកផ្គត់ផ្គង់ ( *អ្នកលក់ទំនិញឱ្យគេ*) ប៉ុន្តែច្បាប់នេះបានកំណត់ផ្តល់សិទ្ធិនិងកាតព្វកិច្ចឱ្យភាគីពីរ ដែលសំខាន់ជាងគេ គឺ ភតិបតី និងភតិកៈ ។

***ទី១. ភតិបតី*** ដែលជាអ្នកជួលចលនវត្ថុឱ្យគេ នៅក្នុងជំពូកទី៣ ច្បាប់បានផ្តល់សិទ្ធិនិងកាតព្វកិច្ចឱ្យគាត់ យ៉ាងច្រើន ប៉ុន្តែសិទ្ធិសំខាន់ជាងគេ គឺសិទ្ធិជាម្ចាស់កម្មសិទ្ធិលើចលនវត្ថុនោះ ។ តាមរយៈសិទ្ធិនេះ ភតិបតីមានសិទ្ធិរឹបអូសយកចលនវត្ថុរបស់ខ្លួនមកវិញបាន នៅពេលដែលភតិកៈ ( *អ្នកសុំជួល*) មិនគោរពតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងភតិសន្យា ។

***ទី២. ភតិកៈ*** ( អ្នកសុំជួល) នៅជំពូកទី៤ ច្បាប់បានផ្តល់សិទ្ធិនិងកាតព្វកិច្ចឱ្យភតិកៈយ៉ាងច្រើនណាស់ដែរ ប៉ុន្តែសិទ្ធិសំខាន់ជាងគេគឺ សិទ្ធិកាន់កាប់និងប្រើប្រាស់ ។ ភតិកៈមានសិទ្ធិបដិសេធចលនវត្ថុនោះចោល ប្រសិនបើចលនវត្ថុនោះ ត្រូវបានគេផ្គត់ផ្គង់មិនសមស្របតាមលក្ខណៈបច្ចេកទេសដែលគាត់ចង់បាន ពោលគឺ មិនត្រឹមត្រូវតាមកិច្ចព្រមព្រៀងផ្គត់ផ្គង់ ។ ម្យ៉ាងទៀតភតិកៈអាចក្លាយជាម្ចាស់លើចលនវត្ថុនោះបាននៅពេលដែលចប់កិច្ចសន្យាបានទិញចលនវត្ថុនោះផ្តាច់យក ហើយបានទូទាត់ថ្លៃឈ្នួល និងបង់រំលោះរួចរាល់ទៅឱ្យភតិបតី ។

ជារួម កិច្ចសន្យាភតិសន្យាហិរញ្ញវត្ថុជាទូទៅមានភាពទន់ភ្លន់ និងរស់រវើក ដោយបើកផ្លូវឱ្យភាគីភតិបតីនិងភតិកៈមានសេរីភាពទូលំទូលាយក្នុងការកំណត់លក្ខខណ្ឌផ្សេងៗ រួមទាំងកាលវិភាគនៃការទូទាត់សង របៀបទូទាត់សងដែលអាចជាប្រាក់ក៏បាន ឬជាទំនិញក៏បាន ។ល។ គឺ អាស្រ័យលើការព្រមព្រៀងគ្នារវាងភាគីទាំងពីរ ។

**ជំពូកទី ៥** លើកឡើងអំពីអាជ្ញាធរអាណាព្យាបាលនិងអំណាចចេញបញ្ជា មាន២ មាត្រា ។ ជំពូកនេះចែងពីប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ ដែលអាចអនុវត្តបានដោយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ឬក្រុមហ៊ុនភតិសន្យាដែលទទួលបានអាជ្ញាប័ណ្ណប្រកបមុខរបរធនាគារពីធនាគារជាតិនៃកម្ពុជា ។ ធនាគារជាតិនៃកម្ពុជាដើរតួនាទី ជាអាណាព្យាបាលលើគ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ។

**ជំពូកទី ៦** លើកឡើងអំពីទណ្ឌកម្ម មាន ១ មាត្រា **ជំពូកទី ៧** លើកឡើងអំពីអន្តរប្បញ្ញត្តិ មាន ១ មាត្រា និង**ជំពូកទី ៨** លើកឡើងអំពីអវសានប្បញ្ញត្តិ មាន ២ មាត្រា ។

**អំពីសារៈសំខាន់នៃសេចក្តីព្រាងច្បាប់ភតិសន្យាហិរញ្ញវត្ថុ**

ច្បាប់នេះ មានសារៈសំខាន់ក្នុងការអភិវឌ្ឍប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ និងសហគ្រាសធុនតូចនិងមធ្យម (SME) នៅកម្ពុជា តាមរយៈការទទួលបានប្រភពទុនរយៈពេលវែងពីប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុយកទៅពង្រីកដំណើរការអាជីវកម្មរបស់ខ្លួន និងការផ្តល់សិទ្ធិជូនធនាគារជាតិនៃកម្ពុជា ជាអាជ្ញាធរគ្រប់គ្រងនិងត្រួតពិនិត្យលើប្រតិបត្តិការនេះ ។

ច្បាប់នេះ ក៏ជាឧបករណ៍មួយយ៉ាងសំខាន់សម្រាប់បង្កលក្ខណៈងាយស្រួលឱ្យអ្នកសុំខ្ចី ដូចជា សហគ្រាសធុនតូចនិងមធ្យម (SME) ជាដើម មានលទ្ធភាពកាន់តែច្រើនឡើងក្នុងការទទួលបានហិរញ្ញប្បទានរយៈពេលវែងដើម្បីយកទៅអភិវឌ្ឍអាជីវកម្មរបស់ខ្លួន ដោយមិនបាច់មានវត្ថុបញ្ចាំ ឬក៏មានវត្ថុបញ្ចាំតិចតួច ។

ច្បាប់នេះ ក៏ជាឧបករណ៍សម្រាប់ជួយលើកកម្ពស់ការគ្រប់គ្រងលំហូរសាច់ប្រាក់ឱ្យកាន់តែប្រសើរថែមទៀត ។ ក្នុងករណីភតិសន្យាហិរញ្ញវត្ថុ អ្នកសុំខ្ចីអាចមានលទ្ធភាពរកដើមទុនរយៈពេលវែងបានទាំងដុំ សម្រាប់យកទៅទិញគ្រឿងចក្រ ឬទព្វសម្ភារៈសម្រាប់ពង្រីកអាជីវកម្មរបស់ខ្លួន ហើយដល់ពេលសងវិញ គឺត្រូវសងតាមរូបភាពជាការបង់ថ្លៃឈ្នួលបន្តិចម្តងៗ តាមរយៈការរំលស់ទៅលើថ្លៃចលនវត្ថុនោះ រហូតដល់ចប់កិច្ចសន្យា ។

ម្យ៉ាងទៀតច្បាប់នេះ បានផ្តល់សិទ្ធិយ៉ាងរឹងមាំដល់ភតិបតីដែលជាម្ចាស់កម្មសិទ្ធិលើទព្វសម្ភារៈ ដែលជាកម្មវត្ថុនៃភតិសន្យា ហើយតាមរយៈនេះនឹងជួយលើកទឹកចិត្តអ្នកឱ្យខ្ចី ឱ្យកាន់តែមានទំនុកចិត្តក្នុងការផ្តល់ឥណទានដល់ភតិកៈដែលជាអ្នកសុំខ្ចី ។

**សម្តេច ឯកឧត្តម លោកជំទាវ សមាជិក សមាជិកានៃព្រឹទ្ធសភា ជាទីគោរពដ៏ខ្ពង់ខ្ពស់**

*សរុបមកវិញ* ច្បាប់នេះបានធានាផលប្រយោជន៍ឱ្យភាគីទាំងសងខាងគឺ ភតិបតី និងភតិកៈ ដោយធានាឱ្យធនាគារហ៊ានឱ្យភតិកៈខ្ចី ហើយភតិកៈអាចយកទព្វសម្ភារៈនោះមកប្រើប្រាស់តាមកិច្ចសន្យាបាន ។ ដូច្នេះ ច្បាប់នេះអាចជួយអភិវឌ្ឍវិស័យសហគ្រាសធុនតូចនិងមធ្យម (SME) នៅកម្ពុជាឱ្យមានការរីកចម្រើនស្របតាមយុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាល ។

សេចក្តីដូចបានជម្រាប និងរាយការណ៍ជូនខាងលើ ខ្ញុំសូមគោរព សម្តេច ឯកឧត្តម លោកជំទាវ ដែលជាសមាជិក សមាជិកានៃព្រឹទ្ធសភាដ៏ឧត្តុង្គឧត្តម មេត្តាពិនិត្យ និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពី **ភតិសន្យាហិរញ្ញវត្ថុ** ដោយអនុគ្រោះ ។

**សូមអរគុណ !**